នស/រកត/១២១៨/ ១៤៥៤

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៣៣៣ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/ ១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានៈដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (កបស) ចំនួន ៨ រូបៈ

១. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ប្រធាន កបស មានឋានៈស្មើ **ឧបនាយករដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

២. ឯកឧត្តម **សុន ឆន្ធរ** អនុប្រធាន កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

៣. ឯកឧត្តម **សុខ ចិន្តាសោភា** អនុប្រធាន កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

៤. ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អនុប្រធាន កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

៥. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** អនុប្រធាន កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

៦. ឯកឧត្តម **ចន្ទរ៉ី ចិស្សុត** អនុប្រធាន កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

៧. ឯកឧត្តម **ជូ ចិជិត្ត** អនុប្រធាន កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន

៨. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** អនុប្រធានប្រចាំការ កបស មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

[illegible]

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៨*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**